ISSN 1810-6358

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

**CDRI-Cambodia's Leading Independent Development Policy Research Institute**

# របាយការណ៍ថ្មីៗស្តីពីសេដ្ឋកិច្ចកម្ពុជា

# Flash Report on the Cambodian Economy

តុលា ២០០៧ / October 2007

ផាន់ ដាលីស / **Phann Dalis**

ប៉ុន ដូរីណា / **Pon Dorina**

ហ៊ីង វុត្ថា / **Hing Vutha**

ភីម រុនស៊ីណារិទ្ធិ / **Phim Runsinarith**

បកប្រែដោយៈ យូ សិទ្ធីរិទ្ធ និង យេន សុផានី

ភ្នំពេញ កម្ពុជា

**Phnom Penh, Cambodia**

**TO SUBSCRIBE, PLEASE CONTACT:**

*Office Address:* #56, Street 315, Tuol Kork, Phnom Penh, Cambodia, *Postal Address:* CDRI, PO Box 622 Phnom Penh, Cambodia
*Tel:* (855-23) 881-384/881-701/881-916/883-603 *Fax:* (855-23) 880-734 *E-mail:* pubs@cdri.forum.org.kh. *Web site:* http://www.cdri.org.kh

# សកម្មភាពសេដ្ឋកិច្ចសំខាន់ៗរបស់កម្ពុជា

# Main Economic Activities of Cambodia

នៅត្រីមាសទី២ ២០០៧ គំរោងវិនិយោគគិតជាទ្រព្យសកម្មជាប់លាប់បានអនុម័តសំរាប់វិស័យសេវាកម្ម ថយចុះ ៥៩% ធៀបនឹងត្រីមាសមុនមកត្រឹម ១៣៨,០លានដុល្លារ ។ គំរោងអនុម័តក្នុងវិស័យទេសចរណ៍ធ្លាក់ចុះ ៦១% មកត្រឹម ៥៥,០លានដុល្លារ ប៉ុន្តែគ្មានគំរោងអនុម័តសំរាប់សណ្ឋាគារទេ ចាប់តាំងពីត្រីមាសទីបួន ២០០៦ ។ ធៀបនឹងត្រីមាសទី២ ឆ្នាំ២០០៦ គំរោងបានអនុម័តក្នុងវិស័យសេវាកម្ម ធ្លាក់ចុះអស់ ៩៣% ។

In the second quarter of 2007, fixed asset investment approvals in the services sector declined by 59 percent from the preceding quarter to USD138.0 m. Tourism approvals dropped by 61 percent to USD55.0 m, while there have been no approvals for hotels since fourth quarter 2006. Compared to the same quarter in 2006, services approvals fell by 93 percent

**Private Investment in Service Sector Approvals by CDC**
2004 Q3–2007 Q2




*Including expansion projects.*
Source: Council for the Development of Cambodia

នៅខែកក្កដា ២០០៧ ចំនួនភ្ញៀវមកដល់កម្ពុជាសរុប កើន ១៣% ធៀបនឹងខែមុន ដល់ ១៤៣.៣១០នាក់ ។ ភ្ញៀវមកដល់តាមផ្លូវអាកាស មាន ៦៦% នៃភ្ញៀវសរុប ឯតាមផ្លូវគោកមាន ៣២% និង តាមផ្លូវទឹក ២% ។ ដោយឡែកចំពោះភ្ញៀវមកដល់តាមផ្លូវអាកាស អាកាសយានដ្ឋានសៀមរាបទទួលបាន ៥៣% ។ ភ្ញៀវមកសំរាកលំហែមាន ៨៧% នៃភ្ញៀវសរុប និងភ្ញៀវមកក្នុងបំណងពាណិជ្ជកម្ម មាន ៩% ។

In July 2007, total visitor arrivals to Cambodia increased by 13 percent from the previous month, reaching 143,310. Arrivals by air were 66 percent of the total, by land 32 percent and by water 2 percent. Siem Reap airport received 53 percent of total arrivals by air. Holiday visitors were 87 percent of the total and business visitors 9 percent.

**Cambodia: Foreign Visitor Arrivals**
April 2006–July 2007




Source: Ministry of Tourism

នៅខែកក្កដា ២០០៧ ការអនុមតិគំរោងសាងសង់ មាន ៦៤,៧លានដុល្លារ រឺថយចុះ ១៦% ធៀបនឹងខែមុន ។ ការអនុមតិសំណង់ភូមិគ្រឹះ និង ផ្ទះ កើន ៣១% ដល់ ១៩,៥លានដុល្លារ ។ គំរោងផ្ទះល្វែង កើនមួយជាប្រាំ ដល់ ៤១,៧លានដុល្លារ ។ ធៀបនឹងខែដូចគ្នា ឆ្នាំ២០០៦ ការអនុមតិគំរោងសាងសង់សរុប កើនបាន ៤៤% ។

In July 2007, construction approvals were valued at USD64.7 m, a decrease of 16 percent from the previous month. Approvals for villas and houses increased by 31 percent to USD19.5 m. There was a fivefold rise, to USD41.7 m, in flat construction. Compared to the same month in 2006, total construction approvals increased by 44 percent.

**Phnom Penh: Value of Construction Approvals**
April 2006–July 2007




Source: Phnom Penh municipality

# ថ្លៃទំនិញ និង ស្ថានភាពពលករងាយរងគ្រោះ

# Consumer Prices and Vulnerable Workers Survey

នៅខែសីហា ថ្លៃទំនិញទូទៅ កើន ០,០២% ធៀបនឹងខែមុន ។ ថ្លៃម្ហូបអាហារកើន ០,៨% រីឯថ្លៃដឹកជញ្ជូន និង ទូរគមនាគមន៏ ធ្លាក់ចុះ ០,៥% ។ ពីមួយឆ្នាំទៅមួយឆ្នាំ ថ្លៃទំនិញទូទៅកើន ៥,២% ថ្លៃម្ហូបអាហារកើន ៩,៨% និង ថ្លៃដឹកជញ្ជូននិងទូរគមនាគមន៏ កើន ២,៩% ។

In August, overall prices increased by 0.02 percent from a month earlier. Food prices rose by 0.8 percent, while transportation and communication costs fell by 0.5 percent. Year-on-year, overall prices increased by 5.2 percent, food prices rising by 9.8 percent and transportation and communication costs by 2.9 percent.

**Phnom Penh: Consumer Price Index**

(July–December 2000=100)

June 2006–August 2007




Source: National Institute of Statistics

នៅខែកញ្ញា សាំងលក់ថ្លៃជាមធ្យម ៤០៤៨រៀល/លីត្រ រឺ កើន ១,៥% ធៀបនឹងខែមុន ។ ថ្លៃម៉ាស៊ូតជាមធ្យមកើន ១,៧% ដល់ ៣២៥៤រៀល/លីត្រ ។ ធៀបនឹងខែដូចគ្នាមួយឆ្នាំមុន ថ្លៃសាំង និង ម៉ាស៊ូត ថយចុះ ៣,១% និង ៣,៦% ។

Gasoline sold at an average of 4048 riels/ℓ in September, an increase of 1.5 percent from the preceding month. Average diesel prices rose by 1.7 percent to 3254 riels/ℓ. Compared to the same month last year, gasoline and diesel prices fell by 3.1 percent and 3.6 percent, respectively.

**Phnom Penh: Gasoline & Diesel Prices**

July 2006–September 2007




Sources: CDRI and National Institute of Statistics

នៅខែសីហា ចំណូលប្រចាំថ្ងៃពិតរបស់អ្នកធាក់ស៊ីក្លូ គិតជាមធ្យមគឺ ៧១២៦រៀល រឺ ថយចុះ ២៣% ធៀបនឹងខែឧសភា ។ រីឯចំណូលប្រចាំថ្ងៃពិតរបស់អ្នករត់ម៉ូតូឌុប ធ្លាក់ចុះ ៣០% មកត្រឹម ៨៩៧៩រៀល និង របស់កម្មករសំណង់គ្មានជំនាញ ថយចុះ ២,៩% មកត្រឹម ៥៩០១រៀល ។ ធៀបនឹងខែដូចគ្នា ឆ្នាំ២០០៦ ចំណូលប្រចាំថ្ងៃពិតរបស់អ្នកធាក់ស៊ីក្លូ កើន ១៨% អ្នករត់ម៉ូតូឌុប កើន ៣៣% រីឯចំណូលរបស់កម្មករសំណង់គ្មានជំនាញ ធ្លាក់ចុះ ២,១% ។

Average real daily earnings of cyclo drivers in August were KHR7126, a decline of 23 percent from May. Real daily earning of motorcycle taxi drivers fell by 30 percent to KHR8979, and of unskilled construction workers by 2.9 percent to KHR5901. Compared to the same month in 2006, average real daily earnings of cyclo drivers increased by 18 percent, motorcycle taxi drivers rose by 33 percent, and real income of unskilled construction workers fell by 2.1 percent.

**Phnom Penh: Vulnerable Workers Real Daily Earnings**

May 2004–August 2007




Source: CDRI.

# ស្ថានភាពអត្រាប្តូរប្រាក់ និង ជំនួយអភិវឌ្ឍន៍ពីក្រៅប្រទេស

# Exchange Rates and External Development Assistance

នៅខែកញ្ញា ប្រាក់រៀលឡើងថ្លៃ ០,០៣% ទល់នឹងដុល្លារUS ធៀបនឹងខែមុន ដោយប្តូរបាន ៤០៨១,៧រៀល/ដុល្លារ ។ ធៀបនឹងខែកញ្ញា ២០០៦ ប្រាក់រៀលឡើងថ្លៃ ២,២% ទល់នឹងប្រាក់ដុល្លារ ។

In September, the riel appreciated from the previous month by 0.03 percent against the US dollar, trading at 4081.7. Compared to September 2006, the riel appreciated 2.2 percent against the dollar.

**Riels per US Dollar**
July 2006–September 2007




Sources: National Bank of Cambodia and CDRI

ប្រាក់រៀលឡើងថ្លៃ ២,៥% ទល់នឹងប្រាក់បាតថៃនៅខែកញ្ញា ដោយប្តូរបានជាមធ្យម ១២៧,១រៀល/បាត ។ ទល់នឹងប្រាក់ដុងវៀតណាម ប្រាក់រៀលឡើងថ្លៃ ០,២% ដោយប្តូរបាន ២៥,៣រៀល/១០០ដុង ។

The riel improved by 2.5 percent against the Thai baht in September, exchanging at an average of 127.1 riels/baht. Against the Vietnamese dong, the riel appreciated by 0.2 percent, exchanging at 25.3 per 100 dong.

**Riels per THB & VND**
July 2006–September 2007




Source: CDRI

អ្នកផ្តល់ជំនួយបានផ្តល់ប្រាក់ ៤៤៣,៦លានដុល្លារ មកអោយកម្ពុជា សំរាប់ការអប់រំពីឆ្នាំ២០០០ ដល់ ២០០៦ ។ ការផ្តល់ជំនួយនេះ មានគោលដៅកែលំអ គោលនយោបាយនិងការរៀបចំផែនការ ការអប់រំថ្នាក់បឋមសិក្សា និងថ្នាក់មូលដ្ឋាន ការអប់រំថ្នាក់មធ្យមសិក្សា សាលារៀននិងសំភារៈ និងការបណ្តុះបណ្តាលដទៃទៀត ។ នៅឆ្នាំ២០០៦ វិស័យអប់រំទទួលបានទឹកប្រាក់ចំនួន ៧១,៥លានដុល្លារ ។

Donors allocated USD443.6 m to Cambodia for education from 2000 to 2006. The aims were to improve sector policy and planning, primary and basic education, secondary education, schools and facilities and other training. In 2006, USD71.5 m was provided for education.

**External Development Assistance Disbursement: Education Sector**
2000–2006




Source: CDC, *Cambodia Aid Effectiveness Report 2007*

# ការអភិវឌ្ឍន៍រូបិយវត្ថុ

# Monetary Developments

រូបិយវត្ថុទូទៅ (M2) កើនតាមអត្រាប្រចាំឆ្នាំ ៣៣% ហើយការផ្គត់ផ្គង់រូបិយវត្ថុ (M1) កើនតាមអត្រាប្រចាំឆ្នាំ ២,២% នៅខែកក្កដា ។ ក្នុងរយៈ១២ខែ រូបិយវត្ថុទូទៅ (M2) កើនបាន ៤៧% ដែលជាអត្រាដូចគ្នានឹងអត្រាសំរាប់រយៈមួយឆ្នាំដល់ខែមិថុនា ។

Liquidity (M2) grew at an annualised rate of 33 percent and money supply (M1) increased at an annualised rate of 2.2 percent in July. Over the previous 12 months, M2 grew at by 47 percent, the same rate as in the year to June.

**Monetary Survey**

May 2006–July 2007




Source: National Bank of Cambodia

នៅខែកក្កដា ឥណទានក្នុងស្រុកកើនតាមអត្រាប្រចាំឆ្នាំ ២១០% ហើយឥណទានក្នុងវិស័យឯកជនកើនតាមអត្រាប្រចាំឆ្នាំ ១៤៤% ។ ក្នុងរយៈ១២ខែ ដល់ខែកក្កដា ឥណទានក្នុងស្រុកកើន ៥៥% ធៀបនឹងកំណើន ៤៥% ក្នុងរយៈមួយឆ្នាំ ដល់ខែមិថុនា ។

In July, domestic credit increased at an annualised rate of 210 percent, and private sector credit grew at an annualised rate of 144 percent. Over the 12 months to July, domestic credit grew by 55 percent, compared to 45 percent in the year to June.

**Domestic Credit**

May 2006–July 2007




Source: National Bank of Cambodia

នៅខែកញ្ញា ឥណទានក្នុងវិស័យឯកជន កើន ៧,៧% ធៀបនឹងខែមុន ដល់ ៤៨៨៩,២ពាន់លានរៀល ហើយទ្រព្យសកម្មបរទេសសុទ្ធ កើន ០,៤% ដល់ ៩០៨៥,៣ពាន់លានរៀល ។ ឥណទានរដ្ឋាភិបាលកើន ០,២% ដល់ ២៩៨,១ពាន់លានរៀល ហើយបញ្ញើរដ្ឋាភិបាលកើន ២,៤% ដល់ ១៧៤១,១ពាន់លានរៀល ។ ក្នុងពេលជាមួយគ្នា បំណុលផ្សេងៗ កើនឡើង ៤,១% ដល់ -៣៤៤៣,៣ពាន់លានរៀល ។ ប្រតិបត្តិការសាច់ប្រាក់ទាំងនេះ បង្កើនរូបិយវត្ថុទូទៅ បាន ២,៤% ដល់ ៩០៨៨,២ពាន់លានរៀល ។

Private sector credit in September increased by 7.7 percent from the preceding month to KHR4889.2 bn, and net foreign assets went up by 0.4 percent to KHR9085.3 bn. Government credit increased by 0.2 percent to KHR298.1 bn, and government deposits rose by 2.4 percent to KHR1741.1 bn. At the same time, "other items" worsened by 4.1 percent to negative KHR3443.3 bn. These monetary operations increased liquidity by 2.4 percent to KHR9088.2 bn.

**Changes in Monetary Assets**

May 2006–July 2007




Source: National Bank of Cambodia

# ពាណិជ្ជកម្មក្រៅប្រទេស
# External Trade

ការនាំចេញរបស់កម្ពុជា មាន ២៨៦,៩លានដុល្លារ នៅខែកក្កដា រឺ ថយចុះ ១0% ធៀបនឹងខែមុន ។ ការនាំចេញក្នុងវិស័យកាត់ដេរ ធ្លាក់ចុះ ១១% មកត្រឹម ២៧៨,៤លានដុល្លារ ការនាំចេញត្រី ធ្លាក់ចុះ ៨,៨% មកត្រឹម 0,២លានដុល្លារ ឯការនាំចេញកៅស៊ូ កើន ៥,៩% ដល់ ៣,៧លានដុល្លារ ។ ការនាំចេញសរុប កើន ៩,៨% បើធៀបនឹងខែដូចគ្នា ឆ្នាំ២00៦ ។

Cambodia’s exports amounted to USD286.9 m in July, a decrease of 10 percent from the previous month. Garment exports dropped by 11 percent to USD278.4 m; fish exports fell by 8.8 percent to USD0.2 m; rubber exports increased by 5.9 percent to USD3.7 m. Total exports, however, increased by 9.8 percent from the same month in 2006.

**Cambodia: Main Exports**
May 2006–July 2007




Source: *Monthly Bulletin of Statistics, MEF website*

ការនាំចូលបារី ថយចុះ ២0% នៅខែកក្កដា ធៀបនឹងខែមុន មកត្រឹម ៣៧,៦ពាន់លានរៀល រីឯការនាំចូលស៊ីម៉ង់ត៍ កើន ២២% ដល់ ១៨,៣ពាន់លានរៀល ហើយការនាំចូលដែក កើន ៦៦% ដល់ ២៥,៨ពាន់លានរៀល ។ ធៀបនឹងខែដូចគ្នា ឆ្នាំ២00៦ ការនាំចូលបារី ថយចុះ ១,៦% រីឯការនាំចូលស៊ីម៉ង់ត៍ និង ដែក កើន ២៩% និង ៥៦% ។

Cigarette imports decreased in July by 20 percent from the previous month, to KHR37.6 bn, while cement imports increased by 22 percent to KHR18.3 bn, and steel imports rose by 66 percent to KHR25.8 bn. Compared to the same month in 2006, cigarette imports declined by 1.6 percent, while cement and steel imports rose by 29 percent and 56 percent respectively.

**Imports: Cigarettes & Construction Materials**
May 2006–July 2007




Note: Cement revised for April, May and June 2007.
Source: *Monthly Bulletin of Statistics,* MEF website

នៅខែកក្កដា ការនាំចូលសាំងមាន ២៣.៥៩២តោន រឺ កើនឡើង ៣,៨% ធៀបនឹងខែមុន ។ ការនាំចូលម៉ាស៊ូត ធ្លាក់ចុះ 0,៧% ដល់ ៤២.៨៥៦តោន ។ បើគិតជាទឹកប្រាក់ ការនាំចូលសាំង កើន ៤,១% ដល់ ២៩,៨ពាន់លានរៀល រីឯការនាំចូលម៉ាស៊ូត ធ្លាក់ចុះ 0,៤% មកត្រឹម ៤៦,៧ពាន់លានរៀល ។

In July, gasoline imports were 23,592 tonnes, an increase of 3.8 percent from the previous month. Diesel imports decreased by 0.7 percent to 42,856 tonnes. By value, gasoline imports rose by 4.1 percent to KHR29.8 bn, while diesel imports dropped 0.4 percent to KHR46.7 bn.

**Imports: Petroleum Products**
May 2006–July 2007




Source: *Monthly Bulletin of Statistics,* MEF website

# ការអនុវត្តន៍ថវិកាជាតិ

# National Budget Operations

នៅខែឧសភា ២០០៧ ថវិកាចរន្តមានអតិរេក ៤៩,០ពាន់លានរៀល រឺ ៧៣% តិចជាងអតិរេកកាលពីខែមុន ។ នៅខែដូចគ្នា ឆ្នាំ២០០៦ ថវិកាចរន្តមានឱនភាព ៣១,០ពាន់លានរៀល ។

The current budget showed a surplus of KHR49.0 bn in May 2007. This was 73 percent less than the surplus in the previous month. The current budget had a deficit of KHR31.0 bn in the same month in 2006.

**Current Budget Operations**

December 2005–May 2007




Note: Provisional for 2007.
Source: *Monthly Bulletin of Statistics* (MEF website )

នៅខែឧសភា ចំណូលថវិកាចរន្ត ធ្លាក់ចុះ ១,៣% ធៀបនឹងខែមុន មកត្រឹម ៣៣៣,៩ពាន់លានរៀល ។ ចំណូលពីពន្ធក្នុងស្រុក ធ្លាក់ចុះ ៤,៥% មកត្រឹម ២០៩,៨ពាន់លានរៀល ហើយចំណូលមិនមែនពន្ធ ធ្លាក់ចុះ ១៥% មកត្រឹម ៣៩,៩ពាន់លានរៀល រីឯចំណូលពន្ធនាំចេញនាំចូល កើន ១៨% ដល់ ៨៤,៣ពាន់លានរៀល ។

In May, current budget revenue dropped by 1.3 percent from the previous month to KHR333.9 bn. Revenue from domestic taxes fell by 4.5 percent to KHR209.8 bn and non-tax revenue by 15 percent to KHR39.9 bn, while collections from import and export taxes rose by 18 percent to KHR84.3 bn.

**Current Budget Revenue**

December 2005–May 2007




Note: Provisional for 2007.
Source: *Monthly Bulletin of Statistics* (MEF website )

នៅខែឧសភា ចំណាយថវិកាចរន្តកើនមួយជាពីរ ដល់ ២៨៩,០ពាន់លានរៀល ធៀបនឹងខែមុន ។ ចំណាយលើប្រាក់បៀវត្សរ៍ កើនមួយជាពីរ ដល់ ៩៦,៦ពាន់លានរៀល ឧបត្ថម្ភធននិងជំនួយសង្គមកិច្ច កើនមួយជាបួន ដល់ ៩៥,៧ពាន់លានរៀល ហើយចំណាយលើសេវាឯទៀត កើនឡើងមួយជាពីរ ដល់ ៩៦,៨ពាន់លានរៀល ។ ធៀបនឹងខែដូចគ្នា ឆ្នាំ២០០៦ ចំណាយកើនឡើង ១០% ។

Current budget expenditure doubled to KHR289.0 bn in May, compared to the preceding month. Spending on wages doubled to KHR96.6 bn, subsidies and social assistance increased fourfold to KHR95.7 bn and spending on other services doubled to KHR96.8 bn. Spending was 10 percent more than in the same month of 2006.

**Current Budget Expenditure Components**

December 2005–May 2007




Note: Provisional for 2007.
Source: *Monthly Bulletin of Statistics* (MEF website )

# សកម្មភាពសេដ្ឋកិច្ចនៃបណ្ដាប្រទេសជាដៃគូរបស់កម្ពុជា

# Economic Activity of Selected Economic Partners of Cambodia

នៅខែកក្កដា ការនាំចេញទំនិញរបស់ US តំបន់អឺរ៉ូ និង ជប៉ុន កើនឡើង ។ ការនាំចេញទំនិញរបស់ US កើន ៣,៤% ធៀបនឹងខែមុន ដល់ ៩៨,៤៤ពាន់លានដុល្លារ ។ ការនាំចេញទំនិញរបស់តំបន់អឺរ៉ូ និង ជប៉ុន កើន ២,៤% និង ១,៤% ដល់ ១៧១,២៣ពាន់លានដុល្លារ និង ៥៨,៣៣ ពាន់លានដុល្លារ ។

In July, goods exports of the US, Euro zone and Japan increased. US goods exports rose by 3.4 percent from the previous month to USD98.44 bn. Goods exports of the Euro zone and Japan increased by 2.4 percent and 1.4 percent, to USD171.23 bn and USD58.33 bn respectively.

**Goods Exports: US, Euro Zone & Japan**
July 2006–July 2007




Sources: BEA, Eurostat and OECD

នៅខែកក្កដា ចិនមានអតិរេកពាណិជ្ជកម្ម ២៤,៣៥ពាន់លានដុល្លារ ធៀបនឹងអតិរេក ២៦,៩៤ពាន់លានដុល្លារ នៅខែមិថុនា ។ ការនាំចេញសរុប កើន ៤,៣% ធៀបនឹងខែមុន ដល់ ១០៧,៧៤ពាន់លានដុល្លារ រីឯការនាំចូលសរុប កើនលឿនជាងទៀតបាន ៩,២% ដល់ ៨៣,៣៩ ពាន់លានដុល្លារ ។

In July, China recorded a trade surplus of USD24.35 bn, compared to USD26.94 bn in June. Total exports rose by 4.3 percent from the previous month to USD107.74 bn, while total imports increased more rapidly, by 9.2 percent to USD83.39 bn.

**External Trade: China**
July 2006–July 2007




Sources: National Bureau of Statistics of China

នៅខែកក្កដា ម៉ាឡេស៊ី មានអតិរេកពាណិជ្ជកម្ម ២,៣០ពាន់លានដុល្លារ ធៀបនឹងអតិរេក ២,៥២ពាន់លានដុល្លារ នៅខែមិថុនា ។ ទាំងការនាំចេញ និងនាំចូលបានកើនឡើងបន្តិច ធៀបនឹងខែមុន ។ ការនាំចេញ មាន ១៤,៥៦ពាន់លានដុល្លារ ដោយកើនពី ១៤,១៨ពាន់លានដុល្លារ នៅខែមិថុនា ។ រីឯការនាំចូល មាន ១២,២៦ពាន់លានដុល្លារ ធៀបនឹង ១១,៦៦ ពាន់លានដុល្លារ នៅខែមិថុនា ។

In July, Malaysia recorded a trade surplus of USD2.30 bn, compared to USD2.52 bn in June. Both exports and imports increased modestly from the previous month. Exports were USD14.56 bn, up from USD14.18 bn in June. Imports were USD12.26 bn, compared to USD11.66 bn. in June.

**External Trade: Malaysia**
July 2006–July 2007




Source: Department of Statistics, Malaysia

# ស្ថានភាពអតិផរណានៃបណ្តាប្រទេសជាដៃគូរបស់កម្ពុជា

# Inflation Rates in Selected Economic Partners of Cambodia

ក្នុងរយៈមួយឆ្នាំដល់ខែកក្កដា ថ្លៃទំនិញទូទៅនៅ US កើន ២,៤% ។ យោងតាមក្រសួងការងារសហរដ្ឋអាមេរិក កំណើននេះ បណ្តាលមកពីការឡើងថ្លៃម្ហូបអាហារ ផ្ទះស្នាក់នៅ សំលៀកបំពាក់ និង ថ្នាំពេទ្យ ។ នៅអំឡុងពេលដូចគ្នា អតិផរណា មានអត្រា ១,៨% នៅតំបន់អឺរ៉ូ និង អត្រា សូន្យ នៅជប៉ុន ។

US consumer prices increased by 2.4 percent in the year to July. According to the US Department of Labor, this increase largely reflected higher charges for food, housing, apparel and medical care. During the same period, the inflation rate was 1.8 percent in the Euro zone and nil in Japan.

## Inflation Rate: US, Euro Zone & Japan

(change from a year earlier)




Note: The latest data available are for July 2007.
Sources: IMF and *Economist* (15 September 2007)

ក្នុងរយៈមួយឆ្នាំដល់ខែកក្កដា ថ្លៃទំនិញទូទៅនៅហុងកុង កើន ១,៥% គឺខ្ពស់ជាងកំណើន ១,៣% នៅខែមុន ។ កំណើននេះបណ្តាលមកពីការឡើងថ្លៃអង្ករ ថ្លៃឈ្នួលផ្ទះឯកជន និងថ្លៃអាហារឆ្អិនស្រាប់ ។ នៅអំឡុងពេលដូចគ្នា ថ្លៃទំនិញទូទៅនៅចិន និង កូរ៉េខាងត្បូង កើន ៥,៦% និង ២,៥% ។

Hong Kong's consumer prices rose by 1.5 percent in the year to July, more than the 1.3 percent increase a month earlier. This largely reflected increases in the prices of pork, private housing rents and meals bought away from home. During the same period, consumer prices in China and South Korea increased by 5.6 percent and 2.5 percent respectively.

## Inflation Rate: China, Hong Kong & South Korea

(change from a year earlier)




Note: The latest data available are for July 2007.
Sources: IMF and *Economist* (15 September 2007)

នៅខែកក្កដា ២០០៧ សន្ទស្សន៍ថ្លៃទំនិញទូទៅនៅសិង្ហបុរី មានកំរិត ២,៦% ខ្ពស់ជាងនៅខែដូចគ្នាមួយឆ្នាំមុន ។ យោងតាមនាយកដ្ឋានស្ថិតិសិង្ហបុរី កំណើននេះបណ្តាលមកពីការឡើងថ្លៃ ម្ហូបអាហារ ការដឹកជញ្ជូននិងទូរគមនាគមន៍ ការថែទាំសុខភាព និង ការសំរាកលំហែ ។ នៅអំឡុងពេលដូចគ្នា អត្រាអតិផរណា គឺ ១,៦% នៅម៉ាឡេស៊ី និង ១,៨% នៅថៃ ។

Singapore's consumer price index in July 2007 was 2.6 percent higher than in the same month a year earlier. The Department of Statistics of Singapore attributed this to higher costs for food, transport and communication, health care and recreation. During the same period, the inflation rate was 1.6 percent in Malaysia and 1.8 percent in Thailand.

## Inflation Rate: Selected ASEAN Countries

(change from a year earlier)




Note: The latest data available are for July 2007.
Sources: IMF and *Economist* (15 September 2007)

# អត្រាប្តូរប្រាក់លើទីផ្សារអន្តរជាតិ
# Exchange Rates in World Markets

នៅខែកញ្ញា ដុល្លារUS ធ្លាក់ថ្លៃទល់នឹងរូបិយវត្ថុចំបងៗ ។ ទល់នឹងប្រាក់អឺរ៉ូ វាប្តូរបាន ០,៧២អឺរ៉ូ/ដុល្លារUS រឺ ធ្លាក់ថ្លៃ ២% ធៀបនឹងខែមុន ។ ទល់នឹងប្រាក់យ៉េនជប៉ុន វាប្តូរបាន ១១៥,០យ៉េន/ដុល្លារUS រឺ ធ្លាក់ថ្លៃ ១,៤% ធៀបនឹងខែសីហា ។ រូបិយវត្ថុរបស់ US មានឱនភាពដោយសារមានការវាយស្មានកាន់តែច្រើនឡើងថា ធនាគារកណ្តាលអាមេរិក នឹងកាត់បន្ថយអត្រាការប្រាក់ជាលើកទីពីរនៅក្នុងឆ្នាំនេះ (ខែតុលា) ដើម្បីជំរុញដល់សេដ្ឋកិច្ចដែលកំពុងធ្លាក់ល្បឿន ។

In September the US dollar depreciated against most major currencies. Against the euro, it traded at 0.72 EUR/USD, a 2 percent loss from a month earlier. Against the Japanese yen, it exchanged at 115.0, a further 1.4 depreciation from August. The US currency declined on increased speculation that the Federal Reserve would cut interest rates for a second time this year (in October) to spur the flagging economy.

**EUR & JPY Per USD**
Sept 2006–Sept 2007 (monthly average)




Source: Federal Reserve Bank of New York

នៅខែកញ្ញា ប្រាក់វ៉ុនកូរ៉េខាងត្បូង ប្តូរបាន ៩២៨,៦០វ៉ុន/ដុល្លារUS រឺ ឡើងថ្លៃ ០,៦% ធៀបនឹងខែសីហា ។ ប្រាក់វ៉ុនឡើងថ្លៃ ក្រោយពេលធនាគារកណ្តាលចេញរបាយការណ៍ថា អ្នកប្រើប្រាស់មានកំណើនទំនុកចិត្ត ដែលជំរុញឱ្យមានការវាយស្មានថា ការលូតលាស់សេដ្ឋកិច្ចនឹងកើនល្បឿន ។ នៅអំឡុងពេលដូចគ្នា ដុល្លារហុងកុងក៏ឡើងថ្លៃ ទល់នឹង ដុល្លារUS ដែរ ដោយប្តូរបាន ៧,៧៨ដុល្លារហុងកុង/ដុល្លារUS ។

In September the South Korean won exchanged at 928.60 per US dollar, a 0.6 percent appreciation from August. The won strengthened after a central bank report showed rising consumer confidence, fuelling speculation that economic growth will quicken. During the same period, the Hong Kong dollar also advanced against its US counterpart, trading at 7.78 HKD/USD.

**KRW & HKD Per USD**
Sept 2006–Sept 2007 (monthly average)




Source: Federal Reserve Bank of New York

ដុល្លារសិង្ហបុរី ឡើងថ្លៃទល់នឹងដុល្លារUS នៅខែកញ្ញា ដោយប្តូរបាន ១,៥១១ដុល្លារសិង្ហបុរី/ដុល្លារUS ធៀបនឹង ១,៥២៣ដុល្លារសិង្ហបុរី/ដុល្លារUS កាលពីខែមុន ។ ប្រាក់បាតថៃ បានធ្លាក់ថ្លៃបន្តិច ដោយប្តូរបាន ៣២,០៦បាត/ដុល្លារUS ។ រូបិយវត្ថុអាស៊ីភាគច្រើនឡើងថ្លៃ ដោយសារមានការវាយស្មានថា អ្នកវិនិយោគទុន នឹងទិញភាគហ៊ុន និងមូលប័ត្រនៅទីផ្សារទើបកើតថ្មី ស្របពេលដែលធនាគារកណ្តាលUS បន្តកាត់បន្ថយអត្រាការប្រាក់ ។

The Singapore dollar gained against the US dollar in September, trading at 1.511 SGD/USD compared to 1.523 a month earlier. The Thai baht slightly depreciated, exchanging at 32.06 per US dollar. Most Asian currencies gained on speculation that investors would buy more emerging-market stocks and bonds as the Federal Reserve keeps cutting interest rates.

**THB & SGD Per USD**
Sept 2006–Sept 2007 (monthly average)




Source: Federal Reserve Bank of New York

# ស្ថានភាពតំលៃទំនិញលើទីផ្សារអន្តរជាតិ
# Commodity Prices in World Markets

នៅខែសីហា អង្ករនៅទីផ្សារពិភពលោក រក្សាថ្លៃនៅដដែល ដោយសន្ទស្សន៍ថ្លៃអន្តរជាតិ (IPO) មានកំរិត ១៤០,៩ ធៀបនឹង ១៤០,៨ នៅកក្កដា ។ នៅថៃ ថ្លៃអង្ករថៃ100%B ធ្លាក់ចុះ ១,៨% ធៀបនឹងខែមុន មកត្រឹម ៣០៣,៨៥ដុល្លារ/តោន ។ នៅ US ថ្លៃអង្ករនាំចេញកើន ០,៧% ធៀបនឹងខែមុន ដល់ ៣៧៤,៥៩ដុល្លារ/តោន ។

World rice prices remained steady in August, with the International Prices Index (IPO) at 140.9, compared to 140.8 in July. In Thailand, the price of Thai 100% B decreased by 1.8 percent from the previous month to USD303.85 per tonne. In the United States, the export price rose by 0.7 percent from the previous month to USD374.59 per tonne.

**Rice: International Prices Index & Export Prices**
August 2006–August 2007




Sources: Osiriz/InfoArroz and InterRice.

នៅខែកញ្ញា ថ្លៃសណ្តែកសៀង និង ពោត បានកើនឡើង ។ សណ្តែកសៀងលក់បាន ៣២៣,៦៥ដុល្លារ/តោន ដោយកើនពី ២៨៩,១៤ដុល្លារ/តោន នៅខែសីហា ។ ពោត លក់ថ្លៃ ១៤៣,១០ដុល្លារ/តោន រឺ ឡើងថ្លៃ ៣,៧% ធៀបនឹងខែមុន ។ នៅខែសីហា ថ្លៃប្រេងឆា កើន ១,២% ធៀបនឹងខែមុន ដល់ ៧៤៤,៦៥ដុល្លារ/តោន ។

In September, the prices of soybeans and maize increased. Soybeans sold at USD323.65 per tonne, up from USD289.14 in August. Maize was USD143.10 per tonne, a 3.7 percent increase from the previous month. In August, the price of palm oil increased by 1.2 percent from the previous month to USD744.65 per tonne.

**Prices: Soybeans, Maize & Palm Oil**
September 2006–September 2007




Source: Food and Agriculture Organisation (FAO)

នៅខែកញ្ញា ប្រេងឆៅ សាំង និង ម៉ាស៊ូត ឡើងថ្លៃ ។ ថ្លៃប្រេងឆៅលក់ដល់ដៃរបស់ OPEC គឺ ៧៥,៥៤ដុល្លារ/ធុង ធៀបនឹង ៦៩,៩៦ ដុល្លារ/ធុង នៅខែសីហា ។ នៅ US Gulf Coast សាំងធម្មតា (អុកតាន ៨៧) ឡើងថ្លៃ ៨,៤% ធៀបនឹងខែមុន ដល់ ៥៥,៨៦សេន/លីត្រ ។ នៅ US Gulf Coast ដដែល ម៉ាស៊ូត (ស្ពាន់ធ័រតិច លេខ២) ឡើងថ្លៃ ៧,៨% ធៀបនឹងខែមុន ដល់ ៥៨,៧៧សេន/លីត្រ ។

In September, the prices of crude oil, gasoline and diesel oil increased. The OPEC spot price of crude oil was USD75.54 per barrel, against USD69.96 in August. Regular gasoline (87 octane) on the US Gulf Coast rose by 8.4 percent from the previous month to 55.86 cents per litre. Diesel (low sulphur No. 2) on the US Gulf Coast increased by 7.8 percent from the previous month, to 58.77 cents per litre.

**Prices: Crude Oil, Gasoline & Diesel**
September 2006–September 2007




Source: US Energy Information Administration

# ព័ត៌មានសេដ្ឋកិច្ច

# Economic News

**ការនាំចេញផលិតផលកាត់ដេររបស់កម្ពុជា កើន ១២% នៅឆមាសទី១ ឆ្នាំ២០០៧:** ការនាំចេញសរុបនៃផលិតផលកាត់ដេររបស់កម្ពុជា កើន ១២% នៅឆមាសទី១ ឆ្នាំនេះ ។ ឯកឧត្តម ចម ប្រសិទ្ធ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម បានប្រាប់ដល់វេទិកាអ្នកទិញរបស់កម្ពុជាថា កំណើននេះគឺដោយសារកម្ពុជាមានស្តង់ដារពលកម្មល្អ ហើយឈ្មួញអន្តរជាតិនៅតែបន្តទិញផលិតផលកាត់ដេរពីកម្ពុជា ។ លោកមានប្រសាសន៍ទៀតថា កម្ពុជាជាអ្នកនាំចេញផលិតផលកាត់ដេរធំបំផុតក្នុងលំដាប់ទី៥ នៅលើពិភពលោក បន្ទាប់ពី ចិន វៀតណាម បង់ក្លាដេស និង ឥណ្ឌូនេស៊ី ។ លោកប្រធានសមាគមរោងចក្រកាត់ដេរកម្ពុជា និយាយថា "វិស័យកាត់ដេរផ្តល់ការងារដល់កម្មករ ៣៣០.០០០នាក់ ក្នុងនោះ កម្មករជាង ៨០% គឺជានារីក្រីក្រនៅជនបទ ហើយប្រាក់ចំណូលរបស់ពួកគេ មានសារៈសំខាន់ខ្លាំងណាស់សំរាប់ក្រុមគ្រួសារពួកគេ"។ លោកបន្តទៀតថា ឧស្សាហកម្មកាត់ដេរជួយទ្រទ្រង់ជីវភាពប្រជាជនយ៉ាងហោចណាស់បាន ១,៧លាននាក់ នៅកម្ពុជា ។ ប៉ុន្តែចំណាយនាំចេញផលិតផលកាត់ដេរក្នុងមួយកុងតឺន័រ នៅតែមានកំរិតខ្ពស់នៅកម្ពុជា និងត្រូវចំណាយពេលជាច្រើនថ្ងៃ ដើម្បីធ្វើទំរង់បែបបទតាមផ្លូវច្បាប់ ។ នៅវៀតណាម គេត្រូវចំណាយប្រហែល ៣០០ដុល្លារ /កុងតឺន័រ និងប្រើពេលតែមួយថ្ងៃប៉ុណ្ណោះសំរាប់ធ្វើទំរង់បែបបទ ។ នៅកម្ពុជា ត្រូវចំណាយអស់ ៧០០-៨០០ដុល្លារ និងត្រូវប្រើពេលបីថ្ងៃ ។

***Cambodia's garment exports increased 12 percent in first half of 2007:*** The total exports of Cambodia's garment products increased by 12 percent in the first half of this year. The exports are up because Cambodia has good labour standards and international buyers continued to buy garments from Cambodia, Cham Prasidh, minister of commerce, told the Cambodia Buyers Forum. Cambodia is the fifth largest garment products exporter in the world, after China, Vietnam, Bangladesh and Indonesia, he said. "The garment industry employs more than 330,000 workers. More than 80 percent of the workers are poor rural women whose earnings are crucial to their families", the chairman of the Garment Manufacturers Association of Cambodia (GMAC) said, adding that the garment industry provides livelihood for at least 1.7 million people in Cambodia. The cost of exporting a container of garment products is still high in Cambodia, and it takes many days for legal procedures, he said. In Vietnam, the price is about USD300 per container, and it takes one day for legal procedures, he said, adding that in Cambodia, the price is USD700 or 800, and it takes three days. *(Cited from Xinhua, 27 September 2007)*

**គំរោងដាំដើមកៅស៊ូ ៨១០០ហិកតា នៅកម្ពុជា:** ក្រុមហ៊ុនអភិវឌ្ឍន៍កៅស៊ូតាន់បៀន-កំពង់ធំ បានចុះហត្ថលេខាលើកិច្ចសន្យាជួលដី ៨១០០ហិកតា នៅខេត្តកំពង់ធំ សំរាប់ដាំដើមកៅស៊ូ និង សង់រោងចក្រកែច្នៃជ័រ ។ កិច្ចសន្យាមានរយៈពេល ៧០ឆ្នាំ និងស្ថិតក្រោមកិច្ចសហប្រតិបត្តិការរវាងរដ្ឋាភិបាលវៀតណាម និងកម្ពុជា ។ គេប៉ាន់ស្មានថា គំរោងមានតម្លៃប្រហែល ៤៨,១លានដុល្លារ ដែលក្នុងនោះក្រុមហ៊ុន តាន់បៀន មានទុន ៥១% សាជីវកម្មឧស្សាហកម្មកៅស៊ូវៀតណាម ២៩% និង សាជីវកម្មសុងដា ២០% ។ ក្រុមហ៊ុនអភិវឌ្ឍន៍កៅស៊ូតាន់បៀន-កំពង់ធំ គ្រោងដាំកៅស៊ូលើផ្ទៃដី ៧៩០០ហិកតា នៅឆ្នាំ២០១០ និងធ្វើការកែច្នៃជ័រកៅស៊ូនៅឆ្នាំ២០២៣ ។

***8100 ha of rubber to be planted in Cambodia:*** Tan Bien-Kompong Thom Rubber Development Company has signed a contract to lease 8100 ha of land in Kompong Thom province for rubber plantations and the building of a latex plant. The contract will be valid for 70 years and is operating under a cooperation programme of the Vietnamese and Cambodian governments. The project is estimated to cost USD48.1 million, of which Tan Bien Rubber Company contributed 51 percent, the Viet Nam Rubber Industry Corporation 29 percent and the Song Da Corporation 20 percent. The Tan Bien-Kompong Thom Rubber Development Company plans to put 7900 ha under rubber by 2010 and put a 26,000 tonne latex processing plant into operation by 2023. *(Cited from Vietnam Economic Times, 26 September 2007)*